ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ៖ ៥៤១ "អ១"ក្រ១១
ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៥១២៦
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ៖ ៣៩២៥
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ៖ ៩៦០
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង៣០ នាទីរសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៥១២៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] **សន់** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សៀង(រស់) ម្តាយឈ្មោះ [redacted] យ៉ា (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖ **៨៩៣៨** "ម"ដ.ឃ.ដ. ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ នៅមណ្ឌលអប់រំកែប្រែទី១(**ស១**)។

២.ឈ្មោះ [redacted] **សៀង** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់ដូ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ ខ្លួនស្នាក់នៅផ្ទះជួល ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ស្រីម៉ាច មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] លី(ស្លាប់) ម្តាយឈ្មោះ [redacted] ហៀង (រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖ **៨៩៣៧** "ម"ដ.ឃ.ដ. ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ នៅមណ្ឌលអប់រំកែប្រែទី១(**ស១**)។

៣.ឈ្មោះ [redacted] **មករា ហៅ យ៉ា** ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតនៅ[redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅផ្ទះជួល ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] អឿន(រស់) ម្តាយ ឈ្មោះ [redacted] សម្បត្តិ(រស់) នៅលីវ ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖ **៨៩៣៩ "ម"ដ.ឃ.ដ.** ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១នៅមណ្ឌលអប់រំកែប្រែទី១(**ម១**)។

-មេធាវីឈ្មោះ [redacted] ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកនៃការិយាល័យមេធាវី **អិល ឌី អរ** មានអាសយដ្ឋាននៅអគារលេខ ៣៥CD ផ្លូវលេខ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សន់ន់**,ឈ្មោះ [redacted] **សៀង** និងឈ្មោះ [redacted] **មករា ហៅយ៉ា** ។

-មេធាវី[redacted] អាសយដ្ឋានផ្ទះលេខ២១៣ ផ្លូវលេខ៣៥៧ ភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សន់ន់**,ឈ្មោះ [redacted] **សៀង** និងឈ្មោះ [redacted] **មករា ហៅយ៉ា** ។

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ផ្លូវលេខ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

<u>អង្គហេតុនៃរឿងមានដូចតទៅ</u>

-នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែលពាក់ព្រឹក ជនជាប់ចោទឈ្មោះ [redacted] សន់ន់, ជនជាប់ចោទឈ្មោះ [redacted] សៀង និងជនជាប់ចោទឈ្មោះ [redacted] មករា ហៅ យ៉ាបានធ្វើសកម្មភាពលួចយកម៉ូតូរបស់ជនរងគ្រោះ ម៉ុត ណារី ម៉ាកMSX ពណ៌ស ផលិតឆ្នាំ២០១៥ ផ្លាកលេខ ភ្នំពេញ 1FG-6278 ០១គ្រឿង និងម៉ូតូរបស់ជនរងគ្រោះឈ្មោះ ស្រួយ រដ្ឋា ម៉ាកហុងដាស្កុបពីពណ៌ក្រហម ផ្លាកលេខភ្នំពេញ 1HW-5922 មួយគ្រឿង ដែលជនរងគ្រោះបានទុកក្នុងបន្ទប់ជួលចាក់សោរករម៉ូតូ និងសោរបន្ទប់ត្រឹមត្រូវ ដោយជនជាប់ចោទបានយកសរសៃលួសទៅឆ្កឹះសោរបន្ទប់ដើម្បីលួចយកម៉ូតូជនរងគ្រោះ។ជនរងគ្រោះបានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែទី១ សមត្ថកិច្ចនគរបាលប៉ុស្តិ៍ទួលសង្កែទី១ បានឃាត់ខ្លួនជនជាប់ចោទទាំងបីនាក់នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០១ រំលងអធ្រាត្រ។

-បានឃើញ របាយការណ៍លេខ: ១៣៥/២១ រ.ប.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៣៩៤៦ អ.ឃ.ដ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ: ៥១១ អ.ឃ.ដ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាដំណោះស្រាយលេខ: ៨៧០ "ម"ដ.ដ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ឆាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សៀង** បានឆ្លើយថា៖ ចំពោះអង្គហេតុនៃការចោទប្រកាន់លើរូបខ្លួន គឺខ្លួនមិនបានប្រព្រឹត្តទេ ។ ចម្លើយដែលបានឆ្លើយកន្លងមកគឺដោយសារសមត្ថកិច្ចធ្វើទារុណកម្ម ប៉ុន្តែខ្លួនមិនមានភស្តុតាងបង្ហាញតុលាការថាខ្លួនមិនបានប្រព្រឹត្តនោះឡើយ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សង់ ទេ ខ្លួនស្គាល់តែឈ្មោះ[redacted] មកវា ។ នៅថ្ងៃកើតហេតុខ្លួនជិះម៉ូតូជាមួយឈ្មោះ[redacted] មកវា រកទិញអីហូប ក៏បានជួបឈ្មោះ [redacted] សង់ ហើយឈ្មោះ សៀង សង់ក៏បានសុំអោយឈ្មោះ[redacted] មកវា ជួយជូនទៅផ្ទះ ។ ខ្លួន និងឈ្មោះ[redacted] មកវា ក៏បានឌុបឈ្មោះ [redacted] សង់ ទៅផ្ទះ ។ លុះពេលជូនឈ្មោះ សៀង សង់ ដល់ផ្ទះហើយ ខ្លួន និងឈ្មោះ[redacted] មកវា ក៏ជិះម៉ូតូត្រលប់មកវិញ ។ ម៉ូតូដែលជិះឌុបឈ្មោះ [redacted] សង់ គឺជាម៉ូតូរបស់ខ្លួន ម៉ាក និច ។ ខ្លួនគឺជាអ្នកលក់ចាប់ហ្វ៊ុយ ពេលល្ងាច ។ ពីមុនមកខ្លួនមិនដែលស្គាល់និងជួបឈ្មោះ [redacted] សង់ ទេ ទើបតែជួបពេលឈ្មោះ [redacted] សង់ ហៅអោយឈ្មោះ[redacted] មកវា ជូនទៅផ្ទះទេប៉ុណ្ណោះ ។ ខ្លួនមិនបានចូលរួមប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ជនជាប់ចោទឈ្មោះ [redacted] **សង់** បានឆ្លើយថា៖ ចម្លើយដែលខ្លួនបានឆ្លើយកន្លងមកនៅតុលាការមិនមានការបង្ខិតបង្ខំទេ ប៉ុន្តែចំពោះចម្លើយនៅសមត្ថកិច្ចគឺមានការធ្វើទារុណកម្មបង្ខំឱ្យឆ្លើយ។ កន្លងមកមិនដែលស្គាល់ឈ្មោះ លី សៀង ទេទើបតែស្គាល់នៅពេលដែលអោយឈ្មោះ[redacted] សៀង និងឈ្មោះ[redacted] មកវា ជូនទៅផ្ទះ ។ ចំពោះម៉ូតូពីរគ្រឿងម៉ាកហុងដាMSX ពណ៌ស សេរីឆ្នាំ២០១៥ ពាក់ស្លាកលេខ ១FG-៦២៧៨ និងម៉ូតូហុងដាស្កុបពី ពណ៌ក្រហម សេរីឆ្នាំ ២០១៧ ពាក់ផ្លាកលេខ ១HW-៥៩៦៦ គឺខ្លួនជាអ្នកលួចតែម្នាក់ឯង ។ ឈ្មោះ[redacted] សៀង និងឈ្មោះ [redacted] មកវា មិនបានដឹងថាខ្លួនទៅលួចម៉ូតូគេទេ ។ ខ្លួនធ្វើសកម្មភាពនៅពេលយប់ លុះព្រឹកឡើងទើបខ្លួនយកទៅលក់ ។ នៅថ្ងៃកើតហេតុពេលខ្លួនកំពុងលួចម៉ូតូគេគឺខ្លួនបានអោយឈ្មោះ[redacted] សៀង និងឈ្មោះ[redacted] មកវា នៅចាំខាងក្រៅដោយខ្លួនប្រាប់ថាខ្លួនចូលទៅផ្ទះមួយភ្លែត ។ ពេលលួចបានហើយខ្លួនបានប្រាប់ អោយឈ្មោះ[redacted] សៀង និងឈ្មោះ [redacted] មកវា ជួយរុញម៉ូតូដែលខ្លួនលួចបានទៅផ្ទះរបស់ខ្លួនបន្ទាប់មកខ្លួនក៏បានអោយឈ្មោះ[redacted] សៀង និងអ៊ុក មកវា ជូនខ្លួនទៅផ្ទះជួលដើម្បីខ្លួនចូលទៅលួចម៉ូតូម្តងទៀត ។ សមត្ថកិច្ចបានឃាត់រូបខ្លួនមុនគេ បន្ទាប់មកទើបឈានទៅដល់ការឃាត់ខ្លួនឈ្មោះ[redacted] សៀង និងឈ្មោះ[redacted] មកវា តាមក្រោយ ។

-ជនជាប់ចោទឈ្មោះ [redacted] **មករា** បានឆ្លើយថា៖ សមត្ថកិច្ចបានឃាត់ខ្លួននៅពេលយប់ ០១យប់ ឃាត់ខ្លួនជាមួយឈ្មោះ [redacted] សៀង ។ ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូនៅផ្ទះជួលមែន ។ ខ្លួនជាអ្នកកាច់កម៉ូតូ ចំណែកឯឈ្មោះ [redacted] សង់ ជាអ្នកគាស់សោរផ្ទះ ។ ម៉ូតូដែលលួចបានមានពីរគ្រឿងម៉ាក SCOOPY មួយគ្រឿង និងម៉ូតូម៉ាក MSX មួយគ្រឿង ឈ្មោះ [redacted] សង់ ជាអ្នកកាច់កម៉ូតូ ។ ឈ្មោះ [redacted] សៀង គឺជាអ្នកចាំមើលផ្លូវ ។ ពេលលួចម៉ូតូបានហើយឈ្មោះ [redacted]សៀង ជាអ្នកជួយរុញម៉ូតូទៅបន្តប់ជួល ។ ម៉ូតូដែលលួចបានគឺឈ្មោះ [redacted] សង់ និងខ្លួន ជាអ្នកយកទៅលក់ ។ ម៉ូតូមួយគ្រឿងលក់បាន៣០០ដុល្លារអាមេរិក បែងចែកលុយគ្នាបានម្នាក់១០០ដុល្លារអាមេរិក ។ នៅសល់ម៉ូតូមួយគ្រឿងទៀតគឺមិនបានលក់ទេ ឈ្មោះ [redacted] សង់ ជាអ្នកទុក ។

-ក្រឡាបញ្ជីអានអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ណារី** នៅមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា៖ នៅយប់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល២១ និង៣០នាទី ខ្លួនបានជិះម៉ូតូម៉ាក MSX125 ចេញពីធ្វើការក្រុមហ៊ុន ដើម្បីធ្វើដំណើរមកកន្លែងផ្ទះជួល នៅទួលសង្កែពេលខ្លួនជិះម៉ូតូ មកបានដាក់ម៉ូតូនៅក្រោមជណ្តើរ បានចោកសោរកម៉ូតូរួច ខ្លួនដើរឡើងជណ្តើរផ្ទះទៅជាន់ទី១ សម្រាករហូត។ លុះព្រឹកឡើងវេលាម៉ោងប្រហែល០៨ និង០០នាទី ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ទើបខ្លួនចុះពីលើផ្ទះមកដល់កន្លែងទុកម៉ូតូ មិនឃើញម៉ូតូក៏ផ្អើលនោឡោបាត់ម៉ូតូតែម្តង។

-ក្រឡាបញ្ជីអានអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ឡង្គា នៅមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា៖ នៅយប់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល២១ និង៣០នាទី ខ្លួនបានជិះម៉ូតូម៉ាកស្កុបពី ចេញពីធ្វើការក្រុមហ៊ុន ដើម្បីធ្វើដំណើរមកកន្លែងផ្ទះជួល នៅទួលសង្កែ ពេលខ្លួនជិះម៉ូតូ មកផ្ទះបានដាក់ម៉ូតូនៅក្រោមជណ្តើរ បានចាក់សោរកម៉ូតូរួច ខ្លួនដើរឡើងជណ្តើរផ្ទះជាន់ទី១ សម្រាករហូត។ លុះព្រឹកឡើងវេលាម៉ោង០៨ និង០០នាទី ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ទើបខ្លួនចុះពីលើផ្ទះមកដល់កន្លែងទុកម៉ូតូមកឃើញ ក៏ផ្អើលរោទ្បាបាត់ ម៉ូតូតែម្តង។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកឃើញថា តាមភស្តុតាងឃើញថាជនជាប់ចោទឈ្មោះ [redacted] **សន់ន**,ឈ្មោះ [redacted] **សៀង** និងឈ្មោះ [redacted] **មករា ហៅយ៉ា** ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ផ្លូវលេខ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ តំណាងអយ្យការរក្សាការចោទប្រកាន់ និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីស្តាប់ការសាកសួរដេញដោយរួចមកឃើញថាតាមចម្លើយរបស់កូនក្តីខ្លួនឈ្មោះ [redacted] **សៀង** គឺកូនក្តីខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដូចនេះប្តឹងសុំឱ្យតុលាការឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។ ចំពោះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] **សន់ន និងឈ្មោះ** [redacted] **មករា ហៅយ៉ា** បានសារភាពចំពោះអង្គហេតុដែលបានចោទប្រកាន់ខាងលើ ហើយបានសហការជាមួយតុលាការក្នុងការផ្តល់ចម្លើយ និងស្នើសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សន់ន** បានស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយឱ្យខ្លួនផង ដោយខ្លួនបានដឹងកំហុសហើយ ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សៀង** បានស្នើសុំតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **មករា ហៅយ៉ា** បានស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយឱ្យខ្លួនផងដោយខ្លួនបានដឹងកំហុសហើយ។

តុលាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិអោយជនជាប់ចោទ

-ក្រោយពីស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៨៧០ "ម"ដ.ដ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សន់**,ឈ្មោះ[redacted] **សៀង** និងឈ្មោះ [redacted] **មករា ហៅយ៉ា** ទៅជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ផ្លូវលេខ ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចជំនុំជម្រះសំណុំរឿងនេះ ស្របតាមមាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.អំពើរបស់ជនជាប់ចោទ ដែលបានបង្ហាញនៅក្នុងដីកាសម្រេចបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ គឺនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែលពាក់ព្រឹក ជនជាប់ចោទឈ្មោះ [redacted] សន់, ជនជាប់ចោទឈ្មោះ [redacted] សៀង និងជនជាប់ចោទឈ្មោះ[redacted] មករា ហៅ យ៉ាបានធ្វើសកម្មភាពលួចយកម៉ូតូរបស់ជនរងគ្រោះ [redacted] ណារី ម៉ាកMSX ពណ៌ស ផលិតឆ្នាំ២០១៥ ផ្លាកលេខ ភ្នំពេញ 1FG-6278 ០១គ្រឿង និងម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] រដ្ឋា ម៉ាកហុងដាស្កុបពីពណ៌ក្រហម ផ្លាកលេខភ្នំពេញ 1HW-5922 មួយគ្រឿង ដែលជនរងគ្រោះបានទុកក្នុងបន្ទប់ជួលចាក់សោរករម៉ូតូ និងសោរបន្ទប់ត្រឹមត្រូវដោយជនជាប់ចោទបានយកសរសៃលួសទៅឆ្កុះសោរបន្ទប់ដើម្បីលួចយកម៉ូតូជនរងគ្រោះ ។ ជនរងគ្រោះបានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែទី១ សមត្ថកិច្ចនគរបាលប៉ុស្តិ៍ទួលសង្កែទី១ បានឃាត់ខ្លួនជនជាប់ចោទទាំងបីនាក់នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០១ រំលងអធ្រាត្រ។

៣.ជនជាប់ចោទឈ្មោះ [redacted] សន់ បានឆ្លើយថា៖ ចម្លើយដែលខ្លួនបានឆ្លើយកន្លងមកនៅតុលាការមិនមានការបង្ខិតបង្ខំទេ ប៉ុន្តែចំពោះចម្លើយនៅសមត្ថកិច្ចគឺមានការធ្វើទារុណកម្មបង្ខំឱ្យឆ្លើយ ។ កន្លងមកមិនដែលស្គាល់ឈ្មោះ[redacted] សៀង ទេទើបតែស្គាល់នៅពេលដែលអោយឈ្មោះ [redacted] សៀង និងឈ្មោះ [redacted] មករា ជូនទៅផ្ទះ ។ ចំពោះម៉ូតូពីរគ្រឿងម៉ាកហុងដា MSX ពណ៌ស សេរីឆ្នាំ២០១៥ ពាក់ស្លាកលេខ ១FG-៦២៧៨ និងម៉ូតូហុងដាស្កុបពី ពណ៌ក្រហម សេរីឆ្នាំ២០១៧ ពាក់ផ្លាកលេខ ១HW-៥៩៦៦ គឺខ្លួនជាអ្នកលួចតែម្នាក់ឯង ។ ឈ្មោះ[redacted] សៀង និងឈ្មោះ [redacted] មករា មិនបានដឹងថាខ្លួនទៅលួចម៉ូតូគេទេ ។ ខ្លួនធ្វើសកម្មភាពនៅពេលយប់ លុះព្រឹកឡើងទើបខ្លួនយកទៅលក់ ។ នៅថ្ងៃកើតហេតុពេលខ្លួនកំពុងលួចម៉ូតូគេគឺខ្លួនបានអោយឈ្មោះ[redacted] សៀង និងឈ្មោះ[redacted] មករា នៅចាំខាងក្រៅដោយខ្លួនប្រាប់ថាខ្លួនចូលទៅផ្ទះមួយភ្លែត ។ ពេលលួចបានហើយខ្លួនបានប្រាប់ អោយឈ្មោះ [redacted] សៀង និងឈ្មោះ[redacted] មករា ជួយរុញម៉ូតូដែលខ្លួនលួចបានទៅផ្ទះរបស់ខ្លួនបន្ទាប់មកខ្លួនក៏បានអោយឈ្មោះ [redacted] សៀង និង[redacted] មករា ជូនខ្លួនទៅផ្ទះជួលដើម្បីខ្លួនចូលទៅលួចម៉ូតូម្តងទៀត ។ សមត្ថកិច្ចបានឃាត់ខ្លួនមុនគេ បន្ទាប់មកទើបឈានទៅដល់ការឃាត់ខ្លួនឈ្មោះ[redacted]សៀង និងឈ្មោះ[redacted] មករា តាមក្រោយ ។

៤.ជនជាប់ចោទឈ្មោះ [redacted] សៀង បានឆ្លើយថា៖ ចំពោះអង្គហេតុនៃការចោទប្រកាន់លើរូបខ្លួន គឺខ្លួនមិនបានប្រព្រឹត្តដូចទេ ។ ចម្លើយដែលបានឆ្លើយកន្លងមកគឺដោយសារសមត្ថកិច្ចធ្វើទារុណកម្ម ប៉ុន្តែខ្លួនមិនមានភស្តុតាងបង្ហាញតុលាការថាខ្លួនមិនបានប្រព្រឹត្តនោះទេ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សន់ ពីមុនទេ ខ្លួនស្គាល់តែឈ្មោះ[redacted] មករា ។ នៅថ្ងៃកើតហេតុខ្លួនជិះម៉ូតូជាមួយឈ្មោះ[redacted] មករា រកទិញអីហូប ក៏បានជួបឈ្មោះ [redacted] សន់ ហើយឈ្មោះ[redacted] សន់ក៏បានសុំអោយឈ្មោះ [redacted] មករា ជួយជូនទៅផ្ទះ ។ ខ្លួន និងឈ្មោះ[redacted] មករា ក៏បានឌុបឈ្មោះ [redacted] សន់ ទៅផ្ទះ ។ លុះពេលជូនឈ្មោះ [redacted]សន់ ដល់ផ្ទះហើយ ខ្លួន និងឈ្មោះ[redacted] មករា ក៏ជិះម៉ូតូត្រលប់មកវិញ ។ ម៉ូតូដែលជិះឌុបឈ្មោះ [redacted] សន់ គឺជាម៉ូតូរបស់ខ្លួន ម៉ាក និច ។ ខ្លួនគឺជាអ្នកលក់ចាប់ហ៊ុយ ពេលល្ងាច ។ ពីមុនមកខ្លួនមិនដែលស្គាល់និងជួបឈ្មោះ សៀង សន់ ទេទើបតែជួបពេលឈ្មោះ [redacted] សន់ ហៅអោយឈ្មោះ[redacted] មករា ជូនផ្ទះទេប៉ុណ្ណោះ ។ ខ្ញុំមិនបានចូលរួមប្រព្រឹត្តអំពើលួចដូចការចោទប្រកាន់ឡើយ ។

-ការឆ្លើយដោះសាររបស់ជនជាប់ចោទថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់តុលាការពុំអាចជឿបានដោយហេតុថាចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលនគរបាលយុត្តិធម៌ បានឆ្លើយសារភាពថាខ្លួនបានចូលរួមធ្វើសកម្មភាពលួចម៉ូតូកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងបី ទៀបភ្លឺ ជាមួយឈ្មោះ [redacted] សន់ និងឈ្មោះ [redacted] មករា។ តុលាការពុំឃើញមានភស្តុតាងណាផ្ទុយពីចម្លើយជនជាប់ចោទសារភាពនោះទេ។ តាមបញ្ញត្តិមាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "តាមគោលការណ៍កំណត់ហេតុមានតម្លៃគ្រាន់តែព័ត៌មានតែប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់(ឯកសារដើម) មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតមានភស្តុតាងផ្ទុយ" ។ហេតុនេះចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាលនគរបាលយុត្តិធម៌តុលាការនៅតែជឿបាន។

៥.ជនជាប់ចោទឈ្មោះ [redacted] មករា ហៅ យ៉ា បានឆ្លើយថា៖ សមត្ថកិច្ចបានឃាត់ខ្លួននៅពេលយប់០១ឃប់ឃាត់ខ្លួនជាមួយឈ្មោះ [redacted] សៀង ។ ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពលួចម៉ូតូនៅផ្ទះជួលមែន ។ ខ្លួនជាអ្នកកាច់កម៉ូតូ ចំណែកឯឈ្មោះ [redacted] សន់ ជាអ្នកគាស់សោរផ្ទះ ។ ម៉ូតូដែលលួចបានមានពីរគ្រឿងម៉ាក SCOOPY មួយគ្រឿង និងម៉ូតូម៉ាក MSX មួយគ្រឿង ឈ្មោះ [redacted] សន់ ជាអ្នកកាច់កម៉ូតូ ។ ឈ្មោះ [redacted] សៀង គឺជាអ្នកចាំមើលផ្លូវ ។ ពេលលួចម៉ូតូបានហើយឈ្មោះ លីសៀង ជាអ្នកជួយរុញម៉ូតូទៅបន្តប់ជួល ។ ម៉ូតូដែលលួចបានគឺឈ្មោះ [redacted] សន់ និងខ្លួន ជាអ្នកយកទៅលក់ ។ ម៉ូតូមួយគ្រឿងលក់បាន៣០០ដុល្លារអាមេរិក បែងចែកលុយគ្នាបានម្នាក់១០០ដុល្លារអាមេរិក ។ នៅសល់ម៉ូតូមួយគ្រឿងទៀតគឺ មិនបានលក់ទេ ឈ្មោះ [redacted] សន់ ជាអ្នកទុក ។

៦.តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ណារី បានឆ្លើយថា៖ នៅយប់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល២១ និង៣០នាទី ខ្លួនបានជិះម៉ូតូម៉ាក MSX125 ចេញពីធ្វើការក្រុមហ៊ុន ដើម្បីធ្វើដំណើរមកកន្លែងផ្ទះជួលនៅទួលសង្កែពេលខ្លួនជិះម៉ូតូ មកបានដាក់ម៉ូតូនៅក្រោមជណ្តើរ បានចោកសោរកម៉ូតូរួច ខ្លួនដើរឡើងជណ្តើរផ្ទះទៅជាន់ទី១ សម្រាករហូត។ លុះព្រឹកឡើងវេលាម៉ោងប្រហែល០៨ និង០០នាទី ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ទើបខ្លួនចុះពីលើផ្ទះមកដល់កន្លែងទុកម៉ូតូ មិនឃើញម៉ូតូក៏ផ្អើលរោឡោបាត់ម៉ូតូតែម្តង។

៧.តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] រដ្ឋា បានឆ្លើយថា៖នៅយប់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល២១ និង៣០នាទី ខ្លួនបានជិះម៉ូតូម៉ាកស្កុបពី ចេញពីធ្វើការក្រុមហ៊ុន ដើម្បីធ្វើដំណើរមកកន្លែងផ្ទះជួលនៅទួលសង្កែ ពេលខ្លួនជិះម៉ូតូ មកផ្ទះបានដាក់ម៉ូតូនៅក្រោមជណ្តើរ បានចាក់សោរកម៉ូតូរួច ខ្លួនដើរឡើងជណ្តើរផ្ទះជាន់ទី១ សម្រាករហូត។ លុះព្រឹកឡើងវេលាម៉ោង០៨ និង០០នាទី ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ទើបខ្លួនចុះពីលើផ្ទះមកដល់កន្លែងទុកម៉ូតូមកឃើញ ក៏ផ្អើលរោឡោបាត់ម៉ូតូតែម្តង។

៨.តាមចម្លើយរបស់ជនជាប់ចោទ ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះ, របាយការណ៍សំយោគលេខ: ១៣៥/២១ រ.ប.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌឬស្សីកែវ ស្របទៅនឹងវត្ថុតាងចាប់យកដែលមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ២២៣១រ.ប.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] **សន់**,ឈ្មោះ [redacted] **សៀង** និងឈ្មោះ [redacted] **មករា ហៅយ៉ា** ពិតជាបានប្រព្រឹត្ត**អំពើ លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្តប់ជួល ផ្លូវលេខ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រាកដមែន។

៩.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សន់,ឈ្មោះ [redacted] សៀង និងឈ្មោះ [redacted] មករា ហៅយ៉ា ជាបទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ដោយសារការប្រព្រឹត្តអំពើលួចរបស់ជនជាប់ចោទ បានប្រព្រឹត្តដោយសារការគាប់គាស់ទម្លុះទម្លាយ។

១០.ជនជាប់ចោទឈ្មោះ [redacted] សន់,ឈ្មោះ [redacted] សៀង និងឈ្មោះ [redacted] មករា ហៅយ៉ា ជានីតិជន ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជនជាប់ចោទអាចយល់ដឹងបានអំពើផលវិបាកដែលខ្លួនបាន

ប្រព្រឹត្ត តែជនជាប់ចោទនៅតែប្រព្រឹត្តដោយចេតនា។

១១.សកម្មភាពរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ដែលត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើសដែលត្រូវផ្តន្ទាទោស ។

១២.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមភស្តុតាងឃើញថាជនជាប់ចោទឈ្មោះ [redacted] **សន់**, ឈ្មោះ [redacted] **សៀង** និងឈ្មោះ [redacted] **មករា ហៅយ៉ា** ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ផ្លូវលេខ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ តំណាងអយ្យការរក្សាការចោទប្រកាន់ និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ មាន លក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណា ។

១៣.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីស្តាប់ការសាកសួរដេញដោយរួចមកឃើញថា តាមចម្លើយរបស់កូនក្តីខ្លួនឈ្មោះ [redacted] **សៀង** មិនមានភស្តុតាងបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់នោះ ដូចនេះប្តឹងសុំឱ្យតុលាការឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។ ចំពោះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] **ហៅ យ៉ា និងឈ្មោះ** [redacted] **សន់** បានសារភាពចំពោះអង្គហេតុដែលបានចោទប្រកាន់ខាងលើ ហើយបានសហការជាមួយតុលាការក្នុងការផ្តល់ចម្លើយ និងស្នើសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ។ ការស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សៀង** ឱ្យកូនក្តីខ្លួនរួចពីបទចោទ និងផ្តល់ស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ សៀង សន់ តុលាការពុំអាចទទួលយកបានទេ ដោយហេតុថាកាល:ទេស:នៃបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទមិនតម្រូវឱ្យជនជាប់ចោទទទួលបាននូវស្ថានសម្រាលបានទេ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] **មករា ហៅ យ៉ា** តុលាការបានផ្តល់នូវស្ថានសម្រាលទោសព្រោះជនជាប់ចោទបានសារភាព និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទបានតម្រូវ ។

១៤.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើ

ក.ឈ្មោះ [redacted] **សន់** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សៀង(រស់) ម្តាយឈ្មោះ [redacted] យ៉ា (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន។

ខ.ឈ្មោះ [redacted] **សៀង** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់ដូ ទីកន្លែងកំណើត [redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ស្រីម៉ាច មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] លី(ស្លាប់) ម្តាយឈ្មោះ [redacted] ហៀង(រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន។

គ.ឈ្មោះ [redacted] **មករា ហៅ យ៉ា** ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] អឿន(រស់) ម្តាយឈ្មោះ [redacted] សម្បត្តិ(រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖គ្មាន។

ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ផ្លូវលេខ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១៥.សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សន់ន**, ឈ្មោះ [redacted]**សៀង** សុំតុលាការមេត្តាជួយបន្ធូរបន្ថយទោស និងជួយរកយុត្តិធម៌ឱ្យខ្លួន។ ការផ្តល់នូវស្ថានសម្រាល តុលាការពុំអាចទទួលយកបានទេ ដោយហេតុថាកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទមិនតម្រូវឱ្យជនជាប់ចោទទទួលបាននូវស្ថានសម្រាលបានទេ ។

១៦.ជនជាប់ចោទឈ្មោះ[redacted] **មករា** បានធ្វើយសារភាពដោយស្មោះត្រង់ គ្មានលាក់លៀមបង្ហាញឱ្យឃើញការពិតទៅលើជនជាប់ចោទឈ្មោះ[redacted] **សន់ន**, ឈ្មោះ [redacted]**សៀង** ពីការចូលរួមប្រព្រឹត្តអំពើល្អច ។ មេធាវីការពារសិទ្ធិឱ្យឈ្មោះ[redacted] **មករា** ក៏បានសំណូមពរឱ្យតុលាការផ្តល់ស្ថានសម្រាលដល់ឈ្មោះ [redacted] **មករា** ផងដែរ។ បុគ្គលិកលក្ខណៈជនជាប់ចោទឈ្មោ[redacted] **មករា** តុលាការគប្បីពិចារណាផ្តន្ទាទោសឱ្យបានទាបជាងជនជាប់ចោទឈ្មោះ[redacted] **សន់ន**, ឈ្មោះ [redacted] **សៀង** ។

១៧.ជនរងគ្រោះ [redacted] **ណារី** និងជនរងគ្រោះឈ្មោះ [redacted] **រដ្ឋា** បានដាក់ពាក្យប្តឹងនៅដំណាក់កាលនគរបាលយុត្តិធម៌តែមិនបានទាមទារសំណងជម្ងឺចិត្តទេ។ នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងចំពោះមុខតុលាការជនរងគ្រោះ ក៏ពុំបានចូលខ្លួនតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាមទារសំណងជំងឺចិត្តស្របតាមមាត្រា៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ គប្បីតុលាការមិនពិចារណានិងសម្រេចអំពីសំណងឡើយ។

<u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោស៖

ក.ឈ្មោះ[redacted]**សន់ន** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ(អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០៥(ប្រាំ)ឆ្នាំ។

ខ.ឈ្មោះ[redacted]**សៀង** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ(អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០៥(ប្រាំ)ឆ្នាំ។

គ.ឈ្មោះ[redacted]**មករា ហៅ យ៉ា** ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ(អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ០៣(បី)ឆ្នាំ។

ពីបទ:**លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ផ្លូវលេខ៩០៧ ក្រុមទី០៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ ឈ្មោះ[redacted] **សន់ន**,ឈ្មោះ [redacted]**សៀង** និងឈ្មោះ[redacted] **មករា ហៅយ៉ា** ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និង គ្រា៖	ហត្ថលេខា និង គ្រា៖	ហត្ថលេខា និង គ្រា៖	ហត្ថលេខា និង គ្រា៖
[redacted]			

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ០៨រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២
ក្រឡាបញ្ជី

[redacted]